ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ០៧

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



កសវ

Work Activities

ប្រចាំខែ កក្កដា ឆ្នាំ ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ព្រំប្រទល់នាទីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប | ១ |
| ២- | កិច្ចប្រជុំសារឡើងវិញលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា | ៣ |
| ៣- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី១ ឆ្នាំ២០១១ | ៤ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១២ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការកំណត់ព្រំប្រទល់នាទីព្រៃលិចទឹក នៅជុំវិញបឹងទន្លេសាប

កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **មិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុក ឆវិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សា លើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ព្រំប្រទល់នាទីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប** ដោយមានការអញ្ជើញចូលរួមពី សំណាក់សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈ រដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃ ទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ព្រៃលិចទឹកត្រូវបានកំណត់ជាកត្តាស្លាប់រស់របស់វិស័យជលផលនិងត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីជលផល ហើយជាដែននេសាទដែលត្រូវថែរក្សាការពារយ៉ាងម៉ឺងម៉ាត់បំផុត ដើម្បីធានាដល់ភាពគង់វង្សនៃប្រភពធនធានជលផលឲ្យមាន និរន្តរភាពទៅថ្ងៃមុខ។

នៅក្នុងឆ្នាំ២០០៥ រដ្ឋបាលជលផលបានធ្វើការបកស្រាយព្រៃលិចទឹកដោយផ្អែកលើរូបថតពីលើអាកាសជាមូលដ្ឋាន របស់គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប។ ដោយយោងតាមទិន្នន័យនៃការបកស្រាយនេះនិងយោងតាមច្បាប់ស្តីពីជលផល បទដ្ឋានក្រោមច្បាប់ដែលពាក់ព័ន្ធត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ជាក់ស្តែងដូចជាអនុក្រឹត្យស្តីពីនីតិវិធីនៃការវិនិយោគ ការ ដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ(១)។



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាន រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ព្រំប្រទល់នា ទីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ក្នុងគោលបំណង កំណត់ព្រំប្រទល់និងផ្ទៃក្រឡានាទីព្រៃលិចទឹកនៅជុំវិញ បឹងទន្លេសាប និងមានគោលដៅ ១-ថែរក្សា ការពារ គ្រប់គ្រង និងប្រើប្រាស់ដែននេសាទ នាទីព្រៃលិចទឹក នៅជុំវិញបឹងទន្លេសាបឲ្យសមស្របតាមបទប្បញ្ញត្តិជាធរ មាន ២-ការពារកន្លែងនេសាទបម្រុងសម្រាប់ដាំ ឬរក្សា ទុកឲ្យព្រៃលិចទឹកដុះឡើងវិញ។

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ព្រំប្រទល់នាទីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប។



សេចក្តីព្រាងអនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើនាទីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប នៃខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចលុបជំពូកទី៣ ដែលនិយាយពីការគ្រប់គ្រងនាទីព្រៃលិចទឹក ព្រោះមានខ្លឹមសារជាន់គ្នានឹងច្បាប់ស្តីពីជលផល និងកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង។

## កិច្ចប្រជុំឡើងវិញលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតគណៈស្ថាបត្យករកម្ពុជា

កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **យូឃាង ថាវរិទ្ធ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឆ្នាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ**សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាង សមាជិកអគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។




សូមរំឭកថា សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃ១២ ខែវិច្ឆិកា និងថ្ងៃ៩ ខែធ្នូ ឆ្នាំ២០០៩។ អង្គប្រជុំនៅ ថ្ងៃ៩ ខែធ្នូ ឆ្នាំ២០០៩ បានស្នើនូវជម្រើសពីរ ៖

១-ធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤។

២-កែសម្រួលសេចក្តីព្រាងព្រះរាជក្រឹត្យនេះកុំឱ្យមានខ្លឹមសារផ្ទុយនឹងច្បាប់ខាងលើនេះ។

ប៉ុន្តែអង្គប្រជុំក៏មានការបារម្ភផងដែរ អំពីភាពមិនអាចអនុវត្តបានដោយជោគជ័យនៃជម្រើសនេះ នាពេលអនាគត។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាឡើងវិញលើសេចក្តីព្រាងថ្មីនេះ ហើយបានកត់សម្គាល់ថាសេចក្តីព្រាងថ្មីនេះ មិនអាចធ្វើឲ្យដូចព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈវិស្វករកម្ពុជាបានទេ ព្រោះវាមិនមានខ្ទាស់នឹងច្បាប់ណាមួយទេ ចំណែកឯសេចក្តីព្រាងព្រះរាជក្រឹត្យនេះខ្ទាស់នឹងមាត្រា១៥ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤។ ដូច្នេះអង្គប្រជុំបានសម្រេចថា គួរធ្វើវិសោធនកម្មមាត្រា១៥ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ៕

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ឆមាសទី១ ឆ្នាំ២០១១*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា សម្រាប់ឆមាសទី១ ឆ្នាំ ២០១១នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១ ខែសីហា ឆ្នាំ ២០១១ ដែលដឹកនាំដោយ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

ក្នុងពេលបច្ចុប្បន្ននេះ សេដ្ឋកិច្ចពិភពលោកនៅតែប្រឈមនឹងហានិភ័យមួយចំនួន ដូចជាការឡើងថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារ ប្រាក់ដុល្លារមិនមានស្ថិរភាព និងបញ្ហាបំណុលអន្តរជាតិជាដើម។ ក្នុងព្រះរាជាណាចក្រកម្ពុជា យើងសង្កេតឃើញថា លំហូរវិនិយោគបរទេសមិនសូវមានសន្ទុះខ្លាំងក្លា និងអតិផរណាមានការកើនឡើងគួរឲ្យព្រួយបារម្ភ។ បញ្ហាទាំងនេះជះឥទ្ធិពលយ៉ាងខ្លាំងមកលើសកម្មភាពសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

យ៉ាងណាក្តី វិស័យសំណង់ ផលិតកម្មវាយនភណ្ឌ និងទេសចរណ៍ ក្នុង ៦ខែដើមឆ្នាំ២០១១ បានបង្ហាញសញ្ញាវិជ្ជមាន ដែលធ្វើឲ្យយើងសង្ឃឹមថា ជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១១។ យើងក៏រំពឹងដែរថា វិស័យកសិកម្ម នឹងរួមវិភាគទានយ៉ាងល្អប្រសើរក្នុងការលូតលាស់នៃសេដ្ឋកិច្ចកម្ពុជា។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ *ដោយមូលហេតុបច្ចេកទេស ក្រសួងផែនការមិនទាន់បញ្ចេញតួលេខសន្ទស្សន៍ថ្លៃខែមិថុនា ២០១១ នៅឡើយ។ ដូច្នេះ យើងមិនទាន់មានអត្រាអតិផរណាសម្រាប់ ៦ខែដើមឆ្នាំនេះទេ។ យ៉ាងណាក្តី តារាងខាងក្រោមបង្ហាញតួលេខខែមិថុនា កក្កដា និងសីហា ដែល ក.ស.វ. បានព្យាករណ៍យោងតាមទិន្នន័យដែលមានដល់ខែឧសភា ឆ្នាំ២០១១។*

---

* ការវិភាគជាលាយលក្ខអក្សរជាការដកស្រង់ចេញពីទិន្នន័យចម្បងៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់នៃតារាងទាំង៥ទេ។ ដូច្នេះអ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរៀងខ្លួន។
* ព័ត៌មាន និងតួលេខពណ៌ **បៃតង** សំដៅលទ្ធផលល្អប្រសើរ និងពណ៌ **ក្រហម** សំដៅលទ្ធផលសម្រាប់ការប្រឹងថ្លែង
* ដើម្បីមានសង្គតិភាពជាមួយក្រមភាសាខ្មែរ សញ្ញាក្បៀសនៅក្នុងសំណេរតាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( ជា Excel ) សញ្ញាក្បៀសជាកំណាត់ខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា[P] | កក្កដា[P] | សីហា[P] | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,៥% | ៩,៧% | ៩,៤% | | | | | ៦,៩% |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| ២០០៩ | ខែដូចគ្នាឆ្នាំមុន | ៨,០% | ៦,២% | -០,៧% | -៣,៩% | -៥,៧% | -៤,៨% | -៣,៩% | -២,៩% | -២,៣% | -១,៥% | ១,៣% | ៨,០% | –០,៧% |

P: តួលេខខែមិថុនា កក្កដា និងសីហា ២០១១ និងប្រចាំឆ្នាំ២០១១ ជាតួលេខព្យាករណ៍( តាមវិធីសាស្ត្រ DECOMPOSITION )

➡ *តារាងខាងលើ អនុញ្ញាតឲ្យយើងមានការសន្និដ្ឋានដូចខាងក្រោម៖*

- តាមតួលេខជាក់ស្តែង អតិផរណាសម្រាប់ ៥ខែដើមឆ្នាំ២០១១ មានអត្រាស្មើនឹង ៤,៥%
- បើយកតួលេខព្យាករណ៍ខែមិថុនាមកប្រើ អតិផរណាសម្រាប់ឆមាសទី១ ឆ្នាំ២០១១ មានអត្រាស្មើនឹង ៥,៤%
- ក.ស.វ. ព្យាករណ៍អត្រាអតិផរណាប្រចាំឆ្នាំ២០១១ ជាបណ្តោះអាសន្ន ៦,៩% ( *អត្រាព្យាករណ៍នឹងប្រែប្រួល នៅពេលមានតួលេខជាក់ស្តែងសម្រាប់ខែថ្មីមកដល់* )។

➡ **អត្រាប្តូរប្រាក់៖**

- នាចុងឆមាសទី១ ឆ្នាំ២០១១ អត្រាប្តូរប្រាក់ រ/ដុល្លារ ស្មើនឹង ៤១១៥រ/១ដុល្លារ បើធៀបនឹងពេលដូចគ្នា ឆ្នាំ២០១០ ប្រាក់រៀល ឡើងថ្លៃ ២.៥%។
- អត្រាប្តូរប្រាក់***រ/បាតថៃ*** ស្មើនឹង ១៣៤រ/១បាត បើធៀបធមាសដូចគ្នា ឆ្នាំ២០១១/២០១០ ប្រាក់រៀលចុះថោក ៣.១% ធៀបនឹងបាត។ យើងកត់សំគាល់ថាបម្រែបម្រួលអត្រា***រ/បាត*** មានទំនាក់ទំនងខ្លាំងជាមួយបម្រែបម្រួលថ្លៃម្ហូបអាហារ។
- ប្រាក់រៀលមាននិន្នាការឡើងថ្លៃធៀបនឹងដុងវៀតណាម។ អត្រាប្តូរប្រាក់***រ/ដុង*** *ថយចុះ៩.៥%* បើប្រៀបធៀបធមាសទី១ដូចគ្នា ឆ្នាំ២០១១/២០១០ ។

## ២ )ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ **ក្នុងធមាសទី១ ឆ្នាំ២០១១ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

- **ចំណូលអនុវត្តបានចំនួន ៣ ១៤៨ ពាន់លានរៀល** *ស្មើនឹង ៤៦% នៃគម្រោងប្រចាំឆ្នាំ* ក្នុងនោះ: **ចំណូលមូលធន ២៤៥ ពាន់លានរៀល** *ស្មើនឹង ៦១% នៃគម្រោង* និង**ចំណូលចរន្ត ២ ៩០៤ ពាន់លានរៀល** *ស្មើនឹង ៤៥% នៃគម្រោង*។
- បើធៀបនឹងធមាសទី១ ឆ្នាំ២០១០ **ចំណូលថវិកាជាតិ** កើនឡើង ៨% ដែលបណ្តាលមកពីចំណូលមូលធនកើនឡើង ៥០% និងចំណូលចរន្តកើនឡើង ៦% ។ ក្រាហ្វខាងក្រោម បង្ហាញបម្រែបម្រួលនៃចំណូលថវិកាជាតិ ជាភាគរយនៃ ផសស។

**ក្រាហ្វ១.** ចំណូលថវិកាជាតិ៖ ប្រៀបធៀបជាអន្តរជាតិ (% នៃផសស)

- ជារួមចំណូលថវិកាជាតិនៃកម្ពុជាមានចំនួនប្រហែល ១២% - ១៣% នៃផសស។ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ អត្រានេះជាមធ្យម មានកំរិតជុំវិញ ២០%។




ប្រភព : តួលេខប្រទេសវៀតណាម និងឡាវ បានពី Key indicators **for Asia and the Pacific 2010: ADB**

➢ ក្នុងចំណូលចរន្ត : ចំណូលសារពើពន្ធ ក្នុង៦ខែដើមឆ្នាំនេះ សម្រេចបាន ២ ៤៦៥ ពាន់លានរៀល *ស្មើនឹង ៤៥% នៃគម្រោងប្រចាំឆ្នាំ* ។ បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១០ ចំណូលនេះកើនឡើង ១០% ដែលបណ្ដាលមកពីពន្ធ និង អាករគយ កើនឡើង ១១% និងចំណូលពន្ធដារ កើនឡើង ១២% ។

| មុខចំណូល | អនុវត្ត គម្រោង | %∆ ធៀបនឹងឆ.១–២០១០ | មុខចំណូល | អនុវត្ត គម្រោង | %∆ ធៀបនឹងឆ .១ –២០១០ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** | ៤៥% | +១០% | **ចំណូលមិនមែនសារពើពន្ធ** | ៤៣% | –១៤% |
| ✓ ពន្ធ-អាករគយ | ៥៤% | +១១% | ✓នេសាទ | ៥១% | –២២% |
| – ពន្ធគយ (របបនាំចូល) | ៤៥% | –៥% | ✓ រុក្ខាប្រមាញ់ | ៧០% | +៤២% |
| – អាករពិសេសលើរបបនាំចូល | ៥០% | +៦% | ✓ សម្បទានរ៉ែ | ៥៨% | –៩៦% |
| – អាករលើតម្លៃបន្ថែមរបបនាំចូល | ៦៣% | +២៦% | ✓ អាកាសចរណ៍ស៊ីវិល | ៦០% | +១២% |
| – អាករនាំចេញ | ២៩២% | ៤៧៥% | ✓ ផលទុនទេសចរណ៍ | ៤១% | +២៩% |
| – អាករបន្ថែមលើផលិតផលគេលសិលា | ៤៩% | –៤% | ✓ ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៤៧% | +១% |
| ✓ ចំណូលពន្ធដារ | ៤៨% | +១២% | ✓ អាករស្នាក់ទូត (លិខិតឆ្លងដែន និង | | |
| – ពន្ធលើប្រាក់បៀវត្ស | ៣៨% | +១៧% | ទិដ្ឋាការ) | ៥៦% | +៣៦% |
| – ពន្ធលើប្រាក់ចំណេញ | ៥៨% | +២៩% | ✓ ត្រួតពិនិត្យគុណភាពផលិតផល | ៥៩% | +៧៧% |
| – ពន្ធលើឈ្នួលផ្ទះ–ដី | ៤១% | +១៧% | ✓ ជួលសហគ្រាស សម្ភារៈ | ៤៣% | +៨% |
| – អាករលើផលរបរ | ២៥% | +៣៤% | ✓ឯកជនភាវូបនីយកម្ម | ៣២% | –១៨% |
| – អាករលើតម្លៃបន្ថែម | ៣២% | –១១% | ✓ លក់អចលនកម្ម | ១៥% | –៥៨% |
| – អាករពិសេស | ៥០% | +២២% | | | |
| – ចំណូលផ្សេងៗ | ៣៨% | +៥% | | | |
| – ពន្ធបរិការខេត្ត–រាជធានី | ៤៧% | +១៨% | | | |
| ✓ ចំណូលសារពើពន្ធផ្សេងៗ | ៦០% | +១៨% | | | |
| – កាស៊ីណូ | ៤៩% | +៦% | | | |
| – អាជ្ញាបណ្ណក្នុងស្រុក | ១០៥% | –៦% | | | |
| – កម្រៃគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ៦៤% | +២៧% | | | |

➢ **គួរកត់សំគាល់ថា** មានការថយចុះ ១១% នៃអាករលើតម្លៃបន្ថែម បើប្រៀបធៀប ៦ខែដូចគ្នា ឆ្នាំ២០១១ និង២០១០។

➢ ចំណាយថវិកាជាតិ ក្នុងឆមាសទី១ ឆ្នាំ២០១១ អនុវត្តបាន ២ ៥៧២ ពាន់លានរៀល ស្មើនឹង ៣០% នៃគម្រោង ក្នុងនោះ: ចំណាយចរន្តសម្រេចបាន ២ ១៦៨ ពាន់លានរៀល ស្មើនឹង ៤៥% នៃគម្រោង និងចំណាយមូលធន ៤០២ ពាន់លានរៀល ស្មើនឹង ១០% នៃគម្រោង។

➢ បើប្រៀបធៀបឆមាសទី១ដូចគ្នា ឆ្នាំ ២០១១/២០១០ ចំណាយថវិកាជាតិកើនឡើង ៦% ក្នុងនោះ: ចំណាយចរន្តកើនឡើង ៩% ប៉ុន្តែចំណាយមូលធនថយចុះ៨% ។

➢ **តុល្យភាពថវិកាជាតិ** ក្នុងឆមាសទី១ ឆ្នាំ២០១១ មានអតិរេក ៥៧៨ ពាន់លានរៀល។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ ស្ថានភាពរូបិយវត្ថុក្នុងឆមាសទី១ ឆ្នាំ២០១១ មានលក្ខណៈដូចខាងក្រោម៖

↳ រូបិយវត្ថុទូទៅ M2 មកដល់ចុងឆមាសទី១មានចំនួន ២២ ០០៨ ពាន់លានរៀល កើនឡើង ២០% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។ ការកើនឡើងនៃ M2 នេះបណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ ១៣% ប្រាក់បញ្ញើចរន្ត ១៦% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ១៨% និងប្រាក់បញ្ញើជារូបិយប័ណ្ណ ២២% ។

↳ សមាសធាតុរូបិយវត្ថុ បង្ហាញថាក្នុង**ឆមាសទី១ ឆ្នាំ២០១១** ប្រាក់រៀលមាន១៨% នៃរូបិយវត្ថុទូទៅ M2 រីឯប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨២% ។ ដូច្នេះបមាណភាគប្រាក់រៀល នៃការផ្គត់ផ្គង់រូបិយវត្ថុក្នុងសេដ្ឋកិច្ចកម្ពុជាមិនមាននិន្នាការឡើងទេ។

ក្រាហ្វ២. សមាសធាតុរូបិយវត្ថុ ឆមាសទី១ ឆ្នាំ ២០១១




↳ យើងកត់សំគាល់ថា ផលធៀប M2/ផសស មានការកើនឡើងក្នុងអំលុង ៣ ឆ្នាំចុងក្រោយ បន្ទាប់ពីឆ្នាំវិបត្តហិរញ្ញវត្ថុសកលលោក ២០០៨។ ក្នុងឆ្នាំ២០១០ បមាណភាគ M2 កើនដល់ ៤១% នៃផសស ប៉ុន្តែបមាណភាគ M1 ក្នុងផសស មានត្រឹមតែ ៦–៧% ប៉ុណ្ណោះ ។ ក្រាហ្វខាងស្តាំជាការប្រៀបធៀប បមាណភាគ M2/**ផសស** សម្រាប់ប្រទេស កម្ពុជា ថៃ និងវៀតណាម។

ក្រាហ្វ៣. ការប្រៀបធៀបរូបិយវត្ថុ M2 : % នៃផសស (គិតតាមថ្លៃចរន្ត)




ប្រភព : តួលេខប្រទេសថៃ និងវៀតណាម បានពី Key indicators for Asia and the Pacific 2010: ADB

↳ ***ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ*** នាឆមាសទី១ ឆ្នាំ២០១១ មានចំនួន ២ ៧៩៧ លានដុល្លារ កើនឡើង១៧% បើធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំ២០១០ ។

↳ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជា*** *ជាទូទៅមានការកើនឡើង* ដោយឡែកក្នុងឆមាសទី១ ឆ្នាំ២០១១ មានចំនួន ៧ ៧១៦ ពាន់លានរៀល កើនឡើង ៧% បើធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ២០១០។

↳ ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** ក្នុងឆមាសទី១ ឆ្នាំ២០១១ មានចំនួន ១៥ ៣៤២ ពាន់លានរៀល កើនឡើង ៣០% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០ ។

↳ ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** ក្នុងឆមាសទី១ ឆ្នាំ២០១១ មាន ២ ០៦២ ពាន់លានរៀល កើនឡើង ៤៩% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។

✧ *អត្រាការប្រាក់ប្រចាំឆ្នាំ៖*

| *ប្រភេទអត្រាការប្រាក់* | *អត្រាចុងឆមាសទី១–២០១១* | *%Δ ធៀបនឹងឆមាសទី១–២០១០* |
|---|---|---|
| ▪ បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៥១% | –១% |
| ▪ កម្ចីជារៀលនៅធនាគារពាណិជ្ជ | ២២,៤៦% | –២% |
| ▪ បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៣៧% | –៦% |
| ▪ កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៦,៨២% | +៤% |

## ៤)ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ កសិកម្ម៖

✧ ជារួមផលិតផលស្រូវ នៅកម្ពុជាមានការកើនឡើងជាលំដាប់។ ក្នុងឆ្នាំ២០១០កន្លងមក ផលិតផលស្រូវ មានកំណើនយ៉ាងខ្ពស់ ៨.៧% និងមានបរិមាណ ៨ ២៤៩ ពាន់តោន។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ផលិតផលស្រូវកើនជាមធ្យម ៧%ប្រចាំឆ្នាំ ។

✧ កំណើនផលិតផលស្រូវ ដោយសារការកើនឡើងនៃផ្ទៃដីដាំដុះ និងទិន្នផលស្រូវ។ ក្នុងឆ្នាំ២០១០ ផ្ទៃដីដាំស្រូវទាំង២រដូវ មានចំនួន ២ ៧៩៦ ពាន់ហិកតា កើនឡើង ៧៧ ពាន់ហិកតា បើធៀបនឹងឆ្នាំ២០០៩។ ចំណែកឯ ទិន្នផលស្រូវក្នុងឆ្នាំ២០១០ ធ្វើបាន ២,៩៥ តោន/១ហិកតា កើនឡើង ១៦១ គ.ក្រ / ហិកតា បើធៀបនឹងឆ្នាំ២០០៩។

✧ ផលិតកម្មនេសាទជាទូទៅ មានការកើនឡើងជារៀងរាល់ឆ្នាំ។ ដោយឡែកក្នុងឆមាសទី១ ឆ្នាំ២០១១ មានចំនួន **៣១៨ ពាន់តោន** ថយចុះ ២% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។ គួរចាប់អារម្មណ៍ថា បរិមាណផលិតផលនេសាទ ក្នុងឆមាសទី១ តែងតែខ្ពស់ជាងក្នុងឆមាសទី២ ។

➡ ឧស្សាហកម្ម៖

✧ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១២៦០ លានគីឡូវ៉ាត់ម៉ោង កើនឡើង ១៥% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។ ក្នុងនោះ វារីអគ្គិសនីមានចំនួន ១១ លានគីឡូវ៉ាត់ម៉ោង កើនឡើង ១៥៧% ។

✧ផលិតកម្មវាយនភណ្ឌ និងស្បែកជើងមាន ១៦០៦ លានដុល្លារ កើនឡើង ១៤% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។

✓ ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស៖

| *ប្រភេទ* | *ចំនួន* : ឆមាសទី១ –២០១១ | *ចំនួន* : ឆមាសទី១ –២០១០ | %Δ |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ៥០ | ២៩ | +៧២% |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៥០ | ៥១ | +១៩៤% |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១១១ | ៧១ | +៥៦% |

➡ **សំណង់៖**

| *ប្រភេទសំណង់* | ពាន់ម$^2$ : ឆមាសទី១ –២០១១ | ពាន់ម$^2$ : ឆមាសទី១ –២០១០ | % Δ |
|---|---|---|---|
| ▪ លំនៅឋាន | ៨៨៨ | ៤៧៤ | +៨៨% |
| ▪ ឧស្សាហកម្ម | ៦០៨ | ២៨៥ | +១១៤ |
| ▪ ពាណិជ្ជកម្ម | ២៧៦ | ៤៧ | +៤៨៦ |
| ▪ ទេសចរណ៍ | ១៣៨ | ៣៤ | +៣០៤ |
| ... | | | |
| ▪ អនុញ្ញាតសរុប | ២០៤៧ | ១០៦១ | +៩៤% |

- សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ២០៤៧ ពាន់ម² កើនឡើង ៩៣% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០ ។ ការអនុញ្ញាតឲ្យសាងសង់ នាឆមាសទី១ ឆ្នាំ២០១១ ជាទឹកប្រាក់ស្មើនឹង ៦៣៨ លានដុល្លារ កើនឡើង ៩៤% បើធៀបនឹងអំលុងពេលដូចគ្នា ឆ្នាំ២០១០ ។
- ក្នុងការអនុញ្ញាតឆមាសទី១ ឆ្នាំ២០១១នេះ សំណង់ដែលពេញនិយមមាន លំនៅឋាន (៤៣% នៃផ្ទៃក្រលាសរុប) និងឧស្សាហកម្ម (៣០% នៃផ្ទៃក្រលាសរុប)។

### ➡ ការងារ៖

| ប្រភេទ | ឆមាសទី១ -២០១១ (នាក់) | ឆមាសទី១ -២០១០ (នាក់) | %Δ |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១៥ ៦៤០ | ២៣ ៩២៩ | -៣៥% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៨ ៩៨៧ | ១៧ ៤៩៧ | +៩% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩ ០៤៤ | ៩ ២៩៥ | -៣% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៩ ៩៤៣ | ៨ ២៦៨ | +២០% |

### ➡ វិនិយោគ៖

- គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./គ.អ.ក. (ថ្មី និងពង្រីក) មានចំនួន ៥៩ គម្រោង កើនឡើង ៣ គម្រោង បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។ ជាទុនវិនិយោគ ការអនុញ្ញាតមានទឹកប្រាក់ចំនួន ២៩៥២ លានដុល្លារ កើនឡើង ១៥២% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។
- ក្នុងទឹកប្រាក់នេះ ១៦១ លានដុល្លារ (៦%) ហូរទៅវិស័យកសិកម្ម និងកសិឧស្សាហកម្ម ៣៣២ លានដុល្លារ (១១%) ហូរទៅវិស័យឧស្សាហកម្ម ១៤៥ លានដុល្លារ (៥%) ហូរទៅវិស័យទេសចរណ៍ និង ២៣១៣ លានដុល្លារទៀត (៧៨%) ហូរទៅវិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ ។
- តាមរយៈគម្រោងទាំងនេះអាចបង្កើតការងារបាន **៨០ពាន់នាក់** កើនឡើង ៣០% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។

### ➡ សេវាកម្ម និងទេសចរណ៍៖

- ការចុះបញ្ជី និងលុបចេញពីបញ្ជី

| ប្រភេទ | ចំនួន: ឆមាសទី១ -២០១១ | ចំនួន: ឆមាសទី១ -២០១០ | %Δ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១៥២៨ | ១១១០ | +៣៨% |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១៩ | ២១ | -១០% |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ១៥៨០ | ១១៧៩ | +៣៤% |

- **ទំនិញឆ្លងកាត់តាមផែ** (សរុប៦ផែ) មានចំនួន ២១៨៧ពាន់តោន កើនឡើង ១០% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។ ក្នុងនោះ៖

| ប្រភេទ | ឆមាសទី១ -២០១១ (ពាន់តោន) | ឆមាសទី១ -២០១០ (ពាន់តោន) | %Δ |
|---|---|---|---|
| ▪ ផែភ្នំពេញ | ៧៣២ | ៦៤៦ | +១៣% |
| ▪ ផែកំពង់សោម | ១១៨៩ | ១០២៩ | +១៥% |
| ▪ ផែស្រែអំបិល និងកោះកុង | ១៦៩ | ១៦១ | +៥% |
| ▪ ផែឧកញ៉ាម៉ុង | ៩៦ | ១៣៥ | -២៩% |

- **អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍**

| ប្រភេទ | ឆមាសទី១ -២០១១ (ពាន់នាក់) | ឆមាសទី១ -២០១០ (ពាន់នាក់) | %Δ |
|---|---|---|---|
| ▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៤៤ | ៤២ | +៦% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ១៦៨៣ | ១៤៦១ | +១៥% |
| ▪ អ្នកទេសចរជាតិចេញក្រៅប្រទេស | ២៩៣ | ២៣២ | +២៦% |
| ▪ អ្នកទេសចរអន្តរជាតិមកដល់កម្ពុជា | ១៣៨៥ | ១២២១ | +១៣% |
| ✓ តាមផ្លូវអាកាស | ៧១៤ | ៦៣២ | +១៣% |
| ✓ តាមផ្លូវគោក និងទឹក | ៦៧១ | ៥៩០ | +១២% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូលក្នុង**ឆមាសទី១ ឆ្នាំ២០១១ **មានចំនួន** ១២ ២៤០**ពាន់លានរៀល** កើនឡើង ២៨% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។ **ក្នុងនោះ**ទំនិញគួរកត់សម្គាល់មាន៖

| ទំនិញ | %Δធៀបនឹងឆមាសទី១ –២០១០ | ទំនិញ | %Δធៀបនឹងឆមាសទី១ –២០១០ |
|---|---|---|---|
| ប្រេងសាំង | +៤% | ជី និងថ្នាំកសិកម្ម | +៧០% |
| ប្រេងម៉ាស៊ូត | +៦% | គេសជ្ជៈ | +១០១% |
| ឧស្ម័ន | +១៨% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +១៧% |
| អគ្គិសនីនាំចូល | +២៣% | ដែកសំណង់ | –៨% |
| រថយន្តសរុប (ព.ល.រ) | +១៧% | ម៉ូតូ | –២៥% |
| រថយន្តសរុប (គ្រឿង) | +១១% | | |
| ត្រាក់ទ័រនិងគោយន្ត | +៤៤% | ផ្លែឈើ និងបន្លែ | –១៤% |
| ស្រូវសាលី | +៣៧% | បារី | –១១% |
| អង្ករ | +៤២% | | |

➡**ការនាំចេញ** ក្នុងឆមាសទី១ ឆ្នាំ២០១១ មានចំនួន ៨ ៦៨៥ ពាន់លានរៀល កើនឡើង ២៦% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១០។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| *ទំនិញ* | %Δធៀបនឹងឆមាសទី១ –២០១០ | *ទំនិញ* | %Δធៀបនឹងឆមាសទី១ –២០១០ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | +២១៥% | អង្ករ | +៣៦០% |
| វាយនភណ្ឌនិងស្បែកជើង | +៣១% | ផលិតផលនេសាទ | –៤៦% |
| កៅស៊ូ | +១១២% | | |

➡ *ក្នុងឆមាសទី១ ឆ្នាំ២០១១ សេដ្ឋកិច្ចកម្ពុជាមានឱនភាពជញ្ជីងពាណិជ្ជកម្ម ៣ ៥៥៥ ពាន់លានរៀល ស្មើនឹង ៨៦៤ លានដុល្លារ ស.រ.អ ។ យោងតាមតួលេខ ឱនភាពជញ្ជីងពាណិជ្ជកម្ម តែងតែមានទំហំធំ ក្នុងឆមាសទី១ ជាងឆមាសទី២ ។*

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុង*ឆមាសទី១ ឆ្នាំ២០១១* សូចនាករសេដ្ឋកិច្ច-សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ឆមាសទី១ –២០១១ (ឯកតា) | %Δ ធៀបនឹង ឆមាសទី១ –២០១០ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | អាករនាំចេញ | ៣៥ ព.ល.រ. | +៤៧៥% | ជាចំបងដោយសារ ការកើនឡើងនៃការ**នាំចេញ**កៅស៊ូ |
| ២. | អាករលើតម្លៃបន្ថែម | ៣១៩ ព.ល.រ. | –១១% | — |
| ៣. | បំណូលពីនេសាទ | ៤,៨ ព.ល.រ. | –២២% | ស្ថិតក្នុងចំណូលមិនមែន សារពើពន្ធ |
| ៤. | ផលទុននៃសកម្មភាពទេសចរណ៍ | ៥៧,៦ ព.ល.រ. | +២៩% | ស្ថិតក្នុងចំណូលមិនមែន សារពើពន្ធ |
| ៥. | ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ | ១៥ ៣៤២ ព.ល.រ. | +៣០% | — |
| ៦. | ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ២ ០៦២ ព.ល.រ. | +៤៩% | — |
| ៧. | ទុនវិនិយោគលើ វិស័យកសិកម្ម និង កសិឧស្សាហកម្ម | ១៦១ លានដុល្លារ | –៤៣% | — |
| ៨. | ការនាំចេញផលិតផលឈើកែច្នៃ | ៩៦ ព.ល.រ. | +២១៥% | — |
| ៩. | ការនាំចេញផលិតផលវាយនភណ្ឌ | ៦ ៩៨១ ព.ល.រ. | +៣១% | — |
| ១០ | ការនាំចេញអង្ករ | ៨៣ ពាន់តោន | +៣៦០% | — |

## ៧) ស្មារតីអង្គប្រជុំ និងសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

**១. ថវិកាជាតិ៖**

ក្នុងឆ្នាំ២០១១ រដ្ឋសភាបានអនុមតិគម្រោងចំណូលថវិកាជាតិប្រចាំឆ្នាំចំនួន ៦ ៨៩៩ ពាន់លានរៀល កើនឡើង ១៣% ធៀបនឹងគម្រោងឆ្នាំ២០១០។ នាឆមាសទី១ ឆ្នាំ២០១១នេះ ចំណូលថវិកាជាតិកើនឡើង ៨% (ទាបជាងអត្រារបស់គម្រោង) និងអនុវត្តបាន ៤៦% បើធៀបនឹងតម្លៃគម្រោង។

ក.ស.វ. បានកត់សម្គាល់ថា ថវិកាជាតិនៅតែពឹងផ្អែកខ្លាំងលើ ពន្ធ-អាករគយ ដែលក្នុងឆមាសទី១នេះ អនុវត្តបានខ្ពស់ជាងគម្រោង ។

ចំពោះចំណាយថវិកាជាតិវិញ ក្នុងឆមាសទី១នេះ ការអនុវត្តគម្រោងមានការយឺតយ៉ាវ ជាពិសេស ចំណាយមូលធន។

យោងតាមការប្រៀបធៀបជាអន្តរជាតិ ចំណូលថវិកាជាតិ គិតជាភាគរយនៃ ផ.ស.ស. របស់ព្រះរាជាណាចក្រកម្ពុជានៅមានកម្រិតទាបនៅឡើយ។

**២. រូបិយវត្ថុ៖**

វិបត្តិនៃប្រាក់ដុល្លារ ដែលចេះតែចុះថ្លៃនៅក្នុងសាកលលោក ជាមូលហេតុចំបងមួយ ដែលធ្វើឲ្យសេដ្ឋកិច្ចដុល្លារូបនីយកម្មនៃកម្ពុជារងនូវអតិផរណាខ្ពស់។

**៣. កសិកម្ម៖**

ក្នុងឆ្នាំ២០១១នេះ ប្រទេសថៃ និងវៀតណាម បានទទួលការបញ្ជាទិញអង្ករយ៉ាងច្រើនសន្ធឹកសន្ធាប់លើសពីឆ្នាំមុនៗ ដែលលើសសក្តានុពលផលិតនៃប្រទេសទាំងពីរ។ ការនេះនឹងធ្វើឲ្យប្រទេសថៃ និងវៀតណាម នឹងបង្កើនការខិតខំប្រមូលទិញស្រូវ ទាំងនៅប៉ែកខាងកើត ទាំងនៅប៉ែកខាងលិច នៃប្រទេសកម្ពុជា ហើយក៏នឹងអាចរំខានដល់កម្ពុជាក្នុងការសម្រេចផែនការបង្កើនការនាំអង្ករចេញ ។

*ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖*

សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា នា៦ខែដើមឆ្នាំ២០១១ សម្រេចបានលទ្ធផលវិជ្ជមានមួយចំនួន ដូចជា វិស័យវាយនភណ្ឌ សំណង់ និងទេសចរណ៍ បានបង្ហាញកំណើនធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

យ៉ាងណាមិញ សេដ្ឋកិច្ច-សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា កំពុងប្រឈមនឹងការលំបាកមួយចំនួនដែរ ដូចជា ថ្លៃទំនិញ និងសេវាកម្ម ចេះតែកើនឡើង ការខ្វះទុនវិនិយោគដើម្បីបង្កើនភាពសកម្មនៃធុរកិច្ច ថ្លៃវត្ថុធាតុដើមខ្ពស់ពេក ដូចជាប្រេងឥន្ធនៈ ជីកសិកម្ម ចំណីសត្វ និងអត្រាការប្រាក់កម្ចីជាដើម ។

ដើម្បីឲ្យសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០១១ សម្រេចបានលទ្ធផលល្អប្រសើរ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមសហការគ្នាឲ្យបានល្អ ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយចាប់ផ្តើមពី ការធានាបានសន្តិសុខ សណ្តាប់ធ្នាប់សង្គម ព្រមទាំង ការបង្កលក្ខណៈឲ្យសកម្មភាពសេដ្ឋកិច្ចមានការកើនឡើង ការទប់ស្កាត់អតិផរណា និងការទាក់ទាញទុនវិនិយោគបរទេស៕

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៧/១១<br>ម៉ោង ០៩ : ០០ នាទី | ដឹកនាំក្រុមការងារ ដើម្បីប្រជុំជាមួយក្រុមការងារភាគីចិន លើគម្រោងសាងសង់អគារព័ត៌មានវិទ្យា នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ០៣/០៧/១១<br>ម៉ោង ០៨ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធប្រាសាទបាពួន ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅប្រាសាទបាពួន ខេត្តសៀមរាប ។ |
| ៣ | ០៤/០៧/១១<br>ម៉ោង ០៩ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាការងារជាមួយក្រុមការងារភាគីចិន នៅបន្ទប់ឯកឧត្តមប្រធាន(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៥/០៧/១១<br>ម៉ោង ០៩ : ០០ នាទី | ដឹកនាំកិច្ចប្រជុំស្តីពីការបង្ហាញគំរូប្លង់ដំបូង នៃអគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យា នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៥ | ០៥/០៧/១១<br>ម៉ោង ១៦ : ០០ នាទី | ដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយគណៈកម្មការព្រលានយន្តហោះ (SCA) នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៦ | ០៦/០៧/១១<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីទទួលដំណើរមាតុភូមិនិវត្តន៍របស់គណៈប្រតិភូ ទៅចូលរួមកិច្ចប្រជុំលើកទី៣៥ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅទីស្នាក់ការកណ្តាលអង្គការយូណេស្កូ នៅទីក្រុងប៉ារីស ប្រទេសបារាំង ក្រោមកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ៧ | ០៦/០៧/១១<br>ម៉ោង ១៥ : ៣០ នាទី<br>" | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់មនុស្សចាស់កម្ពុជា ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៨ | ០៧/០៧/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ÷<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១១ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ០៨/០៧/១១<br>ម៉ោង ០៨ : ៣០នាទី" | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់មនុស្សចាស់កម្ពុជា ។<br>៣-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ១០ | ១១/០៧/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងជាមួយ ឯកឧត្តមអនុប្រធាន នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១១ | ១១/០៧/១១<br>ម៉ោង ១៨ : ០០ នាទី | ប្រជុំពិភាក្សាការងារជាមួយស្ថានទូតកូរ៉េខាងជើង នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១២/០៧/១១<br>ម៉ោង ០៩ : ០០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៣ | ១២/០៧/១១<br>ម៉ោង ១៧ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងជាមួយក្រុមហ៊ុនបារាំង AFD នៅក្រុមហ៊ុន AFD សង្កាត់វត្តភ្នំ រាជធានីភ្នំពេញ ។ |
| ១៤ | ១៣/០៧/១១<br>ម៉ោង ១៦ : ០០ នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ។<br>៣-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៥ | ១៥/០៧/១១<br>ម៉ោង ០៩ : ០០ នាទី | ប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅភូមិគ្រឹះរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** ។ |

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១១ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៦ | ២០-២១/០៧/១១<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមសន្និបាតគណៈកម្មាធិការកណ្តាល លើកទី ៣៦ អាណត្តិទី V របស់គណបក្ស នៅមជ្ឈមណ្ឌលកោះពេជ្រ ។ |
| ១៧ | ២២/០៧/១១<br>ម៉ោង ០៩ : ០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលការអនុវត្តគម្រោងវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍ (Panorama Museum) ក្នុងខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៨ | ២២/០៧/១១<br>ម៉ោង ១៦ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជំនួបពាណិជ្ជកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យា (ITC Business Session) រៀបចំដោយ រដ្ឋាភិបាលម៉ាឡេស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារណាហ្គាវើល ។ |
| ១៩ | ២៣/០៧/១១<br>ម៉ោង ០៨ : ១៥ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកការប្រកួតកីឡាបាល់ទះជនពិការជណ្តើមពានរង្វាន់ពិភពលោក ឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា នៅពហុកីឡាដ្ឋានជាតិអូឡាំពិក ។ |
| ២០ | ២៥/០៧/១១<br>ម៉ោង ០៧ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរជូនលោកជំទាវ **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ជាកិត្តិព្រឹទ្ធបណ្ឌិតនៃរាជបណ្ឌិតសភាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព ។ |
| ២១ | ២៥/០៧/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ ។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២២ | ២៦/០៧/១១<br>ម៉ោង ០៨ : ៣០នាទី<br>(បន្តទៅថ្ងៃរសៀល) | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តតាកែវ ដើម្បីពិភាក្សាលើ៖<br>១-ផ្សព្វផ្សាយលទ្ធផលសន្និបាតរបស់គណៈកម្មាធិការកណ្តាល លើកទី៣៦ អាណត្តិទី៥ របស់គណបក្សប្រជាជនកម្ពុជា ។<br>២-កិច្ចប្រជុំក្រុមការងារចុះជួយមូលដ្ឋានខេត្តតាកែវ ដើម្បីទទួលការណែនាំស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក សមាជិកាព្រឹទ្ធសភា នៅមន្ទីរគណបក្សប្រជាជនកម្ពុជា ខេត្តតាកែវ ។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១១ ( តចប់ )

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ២៣ | ២៧/០៧/១១<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ ។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ។<br>៣-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២៤ | ២៨/០៧/១១<br>ម៉ោង ១៦ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបំពាក់មេដាយជូនលោក Wolfgang Möller ប្រធានអង្គការ GIZ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២៥ | ២៨/០៧/១១<br>ម៉ោង ១៨ : ០០ នាទី | ប្រជុំពិភាក្សាការងារជាមួយស្ថានទូតកូរ៉េខាងជើង នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |



រូបភាពក្នុងកិច្ចប្រជុំស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន សមាជិក-សមាជិកា និង អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១១

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៦/០៧/១១ | ចូលរួមជាកិត្តិយសក្នុងពិធីទទួលដំណើរមោតុភូមិនិវត្តន៍របស់គណៈប្រតិភូ ទៅចូលរួមកិច្ចប្រជុំលើកទី៣៥ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅទីស្នាក់ការកណ្តាលអង្គការយូណេស្កូ នៅទីក្រុងប៉ារីស ប្រទេសបារាំង ក្រោមកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ២ | ១៣/០៧/១១ | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ។<br>៣-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ២២/០៧/១១ | ចូលរួមប្រជុំការងារបន្ថែម ១៨ចំណុច របស់អគារទីស្តីការគណៈរដ្ឋមន្ត្រី ជាមួយភាគីចិន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២៦/០៧/១១ | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តតាកែវ ដើម្បីពិភាក្សាលើ៖<br>១-ផ្សព្វផ្សាយលទ្ធផលសន្និបាតរបស់គណៈកម្មាធិការកណ្តាល លើកទី៣៦ អាណត្តិទី៥ របស់គណបក្សប្រជាជនកម្ពុជា។<br>២-កិច្ចប្រជុំក្រុមការងារចុះជួយមូលដ្ឋានខេត្តតាកែវ ដើម្បីទទួលការណែនាំស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក សមាជិកាព្រឹទ្ធសភា នៅមន្ទីរគណបក្សប្រជាជនកម្ពុជា ខេត្តតាកែវ ។ |
| ៥ | ២៨/០៧/១១ | ចូលរួមជាកិត្តិយសក្នុងពិធីបំពាក់មេដាយជូនលោក Wolfgang Möller ប្រធានអង្គការ GIZ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

# កិច្ចប្រជុំផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋាន ECOSOCC



កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង ១៥:០០នាទី អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង ក្រោមអធិបតីភាព ឯកឧត្តម **ខ៉ាន់ តិរុណា** អគ្គលេខាធិការ ECOSOCC ដោយមានការអញ្ជើញចូលរួមពីសំណាក់អគ្គលេខាធិការរង ប្រធានផ្នែក អនុប្រធានផ្នែក និងមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់ ដើម្បីពិនិត្យលើលទ្ធផលការងារកន្លងមក និងពិភាក្សាលើការងារដែលត្រូវអនុវត្តបន្ត ព្រមទាំងដោះស្រាយការងារខ្លះៗដែលមិនទាន់ដំណើរការទៅដោយរលូន។



ក្រោយពីបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នា ឯកឧត្តម អគ្គលេខាធិការ បានបូកសរុបដោះស្រាយ និងផ្តល់អនុសាសន៍សម្រាប់អនុវត្តការងារបន្ត ដើម្បីបំពេញភារកិច្ចដែលនៅចន្លោះប្រហោងឲ្យមានប្រសិទ្ធភាពជូនក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៕

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម គីម ស៊ុយសាវឡែន | អនុប្រធាន គ.ស.វ. |
| និពន្ធនាយក ៖ | ឯកឧត្តម ប៊ុន ភិរុណ | អគ្គលេខាធិការ គ.ស.វ. |
| និពន្ធអក្ខរាវិរុទ្ធ ៖ | ឯកឧត្តម ឆេង ផ្ទេរគិរី | អគ្គលេខាធិការរង គ.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច ៖ | ឯកឧត្តម អ៊ឹម សារិទ្ធ | សមាជិកបម្រុង គ.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | លោក ស៊ុយ វាសនា | ប្រធានការិយាល័យ គ.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | លោក ចេង ឆុនៈបញ្ញា | ប្រធានការិយាល័យ គ.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | លោក អ៊ុក ឈាន | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន គ.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in